# របាយការណ៍បូកសរុបការងារ ៦ ខែ

| | |
|---|---|
| របាយការណ៍សំរាប់ខែ : | មករា- មិថុនា ឆ្នាំ 2014 |
| ឈ្មោះគម្រោង: | សហគ្រិនវ័យក្មេង |
| ផ្នែក: | បង្កើនប្រាក់ចំណូល |
| អ្នករៀបចំរបាយការណ៍: | លី ពីសី |
| ការបរិច្ឆេទរៀបរៀងរបាយការណ៍: | 03 កក្កដា ឆ្នាំ 2014 |
| ចំនួនអ្នកទទួលផលដោយផ្ទាល់ពីគម្រោងក្នុងរយៈពេលនេះ( ប្រុស/ស្រី) | 125 នាក់ (ភូមិចេក 65 យុវជន និងភូមិព្រៃផ្កាវ 60 យុវជន) |
| ចំនួនអ្នកទទួលផលដោយប្រយោលពីគម្រោងក្នុងរយៈពេលនេះ | 2500 នាក់ (125 គ្រួសារ x 5 សមាជិក x 4 អ្នកជិតខាង) |
| កំណែរបាយការណ៍ | ពង្រាង 1 |

## 1.0 ការណែនាំពីគម្រោង

ក្រុមយុវជនភូមិ ព្រៃផ្កាវបានបង្កើត **សមាគមសន្សំប្រាក់ និងកម្ចី** ដែលមានសមាជិកចំនួន ២៤ នាក់ ដោយមានអ្នកសម្របសម្រួលសហគមន៍ជួយសម្របសម្រួល។

អ្នកសម្របសម្រួលសហគមន៍បានផ្តល់វគ្គបណ្តុះបណ្តាល 2 ដល់យុវជនគឺ **ភាពជាអ្នកដឹកនាំ** មានអ្នក ចូលរួមចំនួន 21 នាក់មកពីភូមិចេក និងភូមិព្រៃផ្កាវ ហើយនឹង **អាជីវកម្មខ្នាតតូច និងការអភិវឌ្ឍន៍ សហគមន៍** ដល់យុវជនភូមិព្រៃផ្កាវចំនួន 25 នាក់។

គម្រោងសហគ្រិនវ័យក្មេង បាននាំយុវជនទៅបោះជំរុំនៅលើកោះទន្សាយ ខេត្តកែប ដែលមានអ្នកចូលរួមចំនួន 56 នាក់។

នាយកប្រតិបត្តិនៃ**អង្គការ** Cambodia Action មកទស្សន:កិច្ចគម្រោងសហគ្រិនវ័យក្មេង នៅភូមិចេក។

អ្នកសម្របសម្រួលសហគមន៍បានចុះជួបពិភាក្សាជាមួយលោកមេឃុំចំនួន 6 ដង ហើយបានចុះជួបពិភាក្សាជាមួយលោក អភិបាលស្រុកចំនួន 1 ដង។

នាយកប្រតិបត្តិ **អង្គការដៃគូនាំផ្លូវនៅកម្ពុជា** (PPC) បានចុះត្រួតពិនិត្យគម្រោងដោយផ្ទាល់ និងផ្តល់អនុសាសន៍ជាប្រចាំផងដែរ។ អ្នកសម្របសម្រួលសហគមន៍ ក៏បានត្រួតពិនិត្យតាមដានការងារក្នុងសហគមន៍ជាប្រចាំផងដែរ។

## 2.0 ផែនការ និងលទ្ធផលសម្រេចបាន

| ផែនការ សកម្មភាព និងលទ្ធផល | កិច្ចការបានបំពេញ | មូលហេតុផ្សេងៗ |
|---|---|---|
| **ភូមិចេក** | | |

| ផែនការ សកម្មភាព និងលទ្ធផល | កិច្ចការបានបំពេញ | មូលហេតុផ្សេងៗ |
|---|---|---|
| បន្តសម្របសម្រួលអោយយុវជនបង្កើតអាជីវកម្មនៅមូលដ្ឋានរបស់គេ | បានធ្វើ និងបន្តធ្វើ | |
| ក្រុមរៀនពីអាជីវកម្មខ្នាតតូច | មានយុវជនបានចូលរួម 25 នាក់ (ស្រី22 នាក់) រៀនរាល់ថ្ងៃសៅរ៍ | |
| បង្រៀន និងណែនាំដំណើរការក្រុមសន្សំប្រាក់ និងកម្ចី | មានយុវជន 24 នាក់ (ស្រី 19 នាក់) បានចូលរួមក្រុមសន្សំប្រាក់។ សន្សំ 10,000 រៀល ក្នុង 1 ខែក្នុង 1 នាក់។ មកដល់ពេលនេះសរុបប្រាក់សន្សំ មាន ចំនួន 10,788,400 រៀល។ | |
| ការជួបជុំក្រុមយុវជន និងពង្រឹងសមត្ថភាពក្រុម | បានធ្វើរួចរាល់ 2 ដង យុវជនបានចូលរួមជាមធ្យម 55 នាក់ (ប្រុស 11)។ | |
| វគ្គបណ្តុះបណ្តាលស្តីពី **ភាពជាអ្នកដឹកនាំ** | បានធ្វើរួចរាល់។ យុវជនចូលរួម 21 នាក់ (10 នាក់ (ប្រុស 2) មកពីភូមិចេក និង 11 នាក់ (ប្រុស 4) មកពីភូមិព្រៃផ្កាវ ហើយវគ្គនេះមានរយៈពេល ពេញ 3 ថ្ងៃ។ | |
| ក្រុមកីឡា និងសុខភាព | ក្នុងក្រុមមានកីឡា 3 ប្រភេទដូចជាៈ បាល់ទះ, ទាត់សី និងវាយ Tennis។ | |
| ក្រុមអាជីវកម្មខ្នាតតូច | - ក្រុមកាត់ដេរមានសមាជិក 3 នាក់មានការកុម្ម៉ង់ច្រើនពីគម្រោងអនាគតត្រចះត្រចង់របស់ PPC<br>- ជាងកាត់សក់ មានអតិថិជនជាច្រើននៅក្នុងសហាគមន៍<br>- ក្រុមចិញ្ចឹមមាន់បានជួសជុលទ្រុងជាថ្មី និងបន្តចិញ្ចឹម និងលក់ជាបន្តបន្ទាប់។ | |
| ការចូលជួបជាមួយអាជ្ញាធរមូលដ្ឋាន | 24 ដងជាមួយមេភូមិ ( 4 ដងក្នុង1ខែ) 6 ដងជាមួយលោកមេឃុំ( 1 ដង ក្នុង 1ខែ) និងជាមួយលោកអភិបាលស្រុក1 ដង។ | |
| សម្របសម្រួលអោយយុវជនចេះភ្ជាប់បណ្តាញអាជីវកម្មរវាងអ្នកខាងក្នុង និងខាងក្រៅភូមិ | បានធ្វើ និង បន្តធ្វើ | |
| ម្ចាស់ជំនួយមកពី **សកម្មភាពកម្ពុជា** **(Cambodia Action)** មកមើលគម្រោង **សហគ្រិនវ័យក្មេង**(YEs) | បានធ្វើរួចរាល់ | |
| **ភូមិព្រៃផ្កាវ** | | |
| ការវាយតម្លៃបុគ្គលិក | បានធ្វើរួចរាល់ | |
| វគ្គបណ្តុះបណ្តាលស្តីពី **អាជីវកម្មខ្នាតតូច និងការអភិវឌ្ឍន៍សហគមន៍** | កំពុងបន្ត | បណ្តុះបណ្តាលរៀងរាល់ថ្ងៃអាទិត្យ |

| ផែនការ សកម្មភាព និងលទ្ធផល | កិច្ចការបានបំពេញ | មូលហេតុផ្សេងៗ |
|---|---|---|
| ការបង្កើត **សមាគមសន្សំប្រាក់ និងកម្ចីភូមិព្រៃផ្កាវ** | មានយុវជន 24 នាក់ (ស្រី 17 នាក់) បានចូលរួមក្រុមសន្សំប្រាក់។ សន្សំ 10,000 រៀល ក្នុង 1ខែ ក្នុង1នាក់។ មកដល់ពេលនេះ សរុបប្រាក់សន្សំមានចំនួន **1,549,800** រៀល។ | |
| ការបង្កើត **ក្រុមកីឡា និងសុខភាព** | បានធ្វើរួចរាល់ មានយុវជនចូលរួម **25** នាក់ (ស្រី **18** ) | |
| វគ្គបណ្តុះបណ្តាលស្តីពី **ការពង្រឹងសហគមន៍** | មិនទាន់បានធ្វើ | រង់ចាំវគ្គបណ្តុះបណ្តាលស្តីពី **អាជីវកម្មខ្នាតតូច និងការអភិវឌ្ឍន៍សហគមន៍** ចប់សិន |
| សម្របសម្រួលអោយយុវជនបង្កើតអាជីវកម្មនៅមូលដ្ឋានរបស់គេ | កំពុងបន្ត | |
| ការចូលជួបជាមួយអាជ្ញាធរមូលដ្ឋាន | បានជួបទំនាក់ទំនងជាមួយលោកមេភូមិ 4ដង គាត់បានគាំទ្រគម្រោង **សហគ្រិនវ័យក្មេង** ជាខ្លាំង | |

## 3.0 ឧបសគ្គ និងដំណោះស្រាយ

យុវជនមួយចំនួននៅមានភាពទន់ខ្សោយក្នុងការរៀបចំផែនការអនាគត ហើយនឹងឯករាជ្យភាពដើម្បីបង្កើតអាជីវកម្មដោយខ្លួនគេផ្ទាល់។ ដូច្នេះហើយអ្នកសម្របសម្រួលសហគមន៍ តែងតែពង្រឹងសមត្ថភាពរបស់ពួកគេតាមរយៈ វគ្គបណ្តុះបណ្តាល ការបង្រៀន បង្ហឹក ណែនាំ ទំនាក់ទំនង ការបង្កើតបណ្តាញអាជីវកម្ម និងការជំរុញ លើកទឹកចិត្តជាដើម។ល។

## 4.0 មេរៀនដែលរៀនបានសំខាន់ៗ

យុវជនដែលបានចូលរួមជាមួយ គម្រោង**សហគ្រិនវ័យក្មេង** ភាគច្រើនបានផ្លាស់ប្តូរផ្នត់គំនិតក្នុងការចង់ចំណាកស្រុកទៅធ្វើការនៅក្រៅស្រុកទៀតទេ ពីព្រោះពួកគេបានដឹង និងយល់ពីផលវិបាកផ្សេងៗនៅ ពេលធ្វើចំណាកស្រុក។

## 5.0 សហគមន៍

សហគមន៍នៃ គម្រោងសហគ្រិនវ័យក្មេង គឺយុវជន, គ្រួសាររបស់យុវជន, អ្នកភូមិ, អាជ្ញាធរមូលដ្ឋាន បុគ្គលិករបស់ គម្រោងសហគ្រិនវ័យក្មេង ហើយនឹងម្ចាស់ជំនួយ។

## 6.0 បញ្ហាយេនឌ័រ

គម្រោងសហគ្រិនវ័យក្មេង ផ្តែកលើសម្បភាពយេនឌ័រ ដែរ 74.40% គឺជាស្ត្រី (ស្រី 93 នាក់/125 យុវជន) ។ អ្នកដឹកនាំក្រុមយុវជនសាមគ្គីគឺជាស្ត្រី។ អ្នកភូមិបានយល់ច្បាស់ថាស្ត្រី និងបុរសមានសិទ្ធិស្មើគ្នា ហើយសង្ឃឹមថាសម្បភាពនេះវានឹងបន្តរីកចំរើនល្អឡើង ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់។

## 7.0 បណ្តាញទំនាក់ទំនងជាមួយរដ្ឋាភិបាល

គម្រោងសហាគ្រិនវ័យក្មេង នឹងបន្តព្យាយាមអោយអស់លទ្ធភាព ដើម្បីបង្កើតបណ្តាញជាមួយ អង្គការ ផ្សេងទៀត តាមដែលអាចធ្វើទៅបាន។

## 8.0 ការអភិវឌ្ឍន៍ធនធានមនុស្ស

ជារៀងរាល់ខែបុគ្គលិក គម្រោងសហាគ្រិនវ័យក្មេង បានចូលរួមប្រជុំប្រចាំខែនៅការិយាល័យ PPC ភ្នំពេញ ដើម្បីរាយការណ៍នូវអ្វីៗដែលបានធ្វើ ហើយនឹងរៀនពីបទពិសោធន៍ផ្សេងៗ របស់គម្រោង /កម្មវិធី ដទៃទៀត នៅក្នុង PPC។

អ្នកសម្របសម្រួលសហាគមន៍បានជួបប្រជុំជាទៀងទាត់ជាមួយ នាយកប្រតិបត្តិ នៅការិយាល័យគម្រោងសហាគ្រិនវ័យក្មេង នៅខេត្តសៀមរាប មួយខែម្តង។

បុគ្គលិក គម្រោងសហាគ្រិនវ័យក្មេង ថ្មី (ភូមិព្រៃផ្គារ) បានរៀនពីរបៀបធ្វើការជាអ្នកសម្របសម្រួលល្អពី អ្នកសម្របសម្រួលមុន (ភូមិចេក) និងពីនាយកប្រតិបត្តិអង្គការ។

បុគ្គលិក គម្រោងសហាគ្រិនវ័យក្មេង បានចូលរួមសិក្ខាសាលានៅខេត្តព្រះសីហនុ។ គម្រោងនឹងបញ្ជូនបុគ្គលិក ទៅចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ពេលដែលមានថវិកាគ្រប់គ្រាន់។

## 9.0 ការត្រួតពិនិត្យ និងវាយតម្លៃសកម្មភាព

នាយកប្រតិបត្តិអង្គការ បានចុះទៅត្រួតពិនិត្យគម្រោងនៅសហាគមន៍ដោយផ្ទាល់ និងបានតាមដាន តាមទូរស័ព្ទ និងបានជួបយុវជន ហើយនឹងក្រុមដឹកនាំយុវជនផងដែរ។ អ្នកសម្របសម្រួលសហាគមន៍បានសរសេររបាយការណ៍ចុះសួរសុខទុក្ខ និងរបាយការណ៍ប្រចាំខែ ទៅអោយ នាយកប្រតិបត្តិ ដើម្បីរាយការណ៍នូវអ្វីដែលជាឧបសគ្គ និងដំណោះស្រាយដែលជួបប្រទះ។ នាយកប្រតិបត្តិបានអានរបាយការណ៍ ហើយអោយនូវអនុសាសន៍ផ្សេងៗ និងដំបូលន្មានល្អៗជាច្រើនដល់អ្នកសម្របសម្រួលសហាគមន៍។

## 10.0 ផែនការអនុវត្តរយៈពេលបន្ទាប់

| សកម្មភាព | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|
| ការប្រជុំប្រចាំខែរបស់បុគ្គលិក | x | x | x | x | x | x |
| ការចុះសហាគមន៍របស់អ្នកគ្រប់គ្រង | x | x | x | x | x | x |
| របាយកាណ៍បូកសរុប ៦ខែក្រោយ | | | | | | x |
| ក្រុមមកពីម៉ាលេស៊ី និងអាមេរិចចុះភូមិ | x | | | | | |
| ម្ចាស់ជំនួយវាយតម្លៃគម្រោង | | | | | x | |
| **ភូមិចេក** | | | | | | |
| អ្នកសម្របសម្រួលចុះសមគមន៍ | x | x | x | x | x | x |
| ប្រជុំក្រុមយុវជនសាមគ្គី | x | x | x | x | x | x |
| ប្រជុំក្រុមអ្នកដឹកនាំយុវជនសាមគ្គី | x | x | x | x | x | x |
| ក្រុមរៀនពីអាជីវកម្មខ្នាតតូច | x | x | x | x | x | x |
| ថ្នាក់អក្ខរកម្ម | x | x | x | x | x | x |

| | | | | | | |
|---|---|---|---|---|---|---|
| ថ្នាក់ភាសាអង់គ្លេស | x | x | x | x | x | x |
| ក្រុមសុខភាព និងកីឡា | x | x | x | x | x | x |
| ក្រុមសន្សំប្រាក់ និងកម្ចី | x | x | x | x | x | x |
| ក្រុមអាជីវកម្មខ្នាតតូច | x | x | x | x | x | x |
| ការជួបជុំក្រុមសាមគ្គីនិងកសាងសមត្ថភាពក្រុម | | | x | | | |
| **ភូមិព្រៃផ្គាំ** | | | | | | |
| អ្នកសម្របសម្រួលចុះសមគមន៍ | x | x | x | x | x | x |
| ប្រជុំក្រុមយុវជនសាមគ្គី | x | x | x | x | x | x |
| ប្រជុំក្រុមអ្នកដឹកនាំយុវជនសាមគ្គី | x | x | x | x | x | x |
| ថ្នាក់ភាសាអង់គ្លេស | x | x | x | x | x | x |
| ថ្នាក់គណិតវិទ្យា | x | x | x | x | x | x |
| ក្រុមសន្សំប្រាក់ និងកម្ចី | x | x | x | x | x | x |
| ក្រុមសុខភាព និងកីឡា | x | x | x | x | x | x |
| វគ្គអាជីវកម្មខ្នាតតូច និងអភិវឌ្ឍន៍សហគមន៍ | x | x | x | x | x | |
| វគ្គការពង្រឹងសហគមន៍ | | | | | | x |
| ការបង្កើតក្រុមអាជីវកម្មខ្នាតតូច | | | | x | | |

## 11.0 ផ្នែកហិរញ្ញវត្ថុ

- គម្រោងមានផ្នែករដ្ឋបាល ឬគណនេយ្យ នៅការិយាល័យ PPC ភ្នំពេញ
- PPC-YEs មានថវិកា $ 7,026.73 បានចំណាយអស់ $ 4,737.54 ក្នុង 6ខែដើមឆ្នាំនេះ។

## 12.0 សកម្មភាពផ្សេងៗ



សកម្មភាពយុវជនបោះជំរុំឆ្នាំ 2014



វគ្គបណ្តុះបណ្តាល "ភាពជាអ្នកដឹកនាំ"



សកម្មភាពក្រុមកាត់ដេរ



អ្នកឧបត្ថម្ភចុះភូមិ